រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០៤០ ស ៣៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



# សេចក្តីណែនាំ

## ស្តីពី

## ការជំរុញផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរដែលធើបចិលត្រលប់ពីប្រទេសថៃ និងប្រជាពលរដ្ឋខ្មែរដែលពុំទាន់មានឯកសារគ្រប់គ្រាន់

ក្នុងស្ថានភាពជាក់ស្តែងបច្ចុប្បន្ន ដែលមានជម្លោះតាមព្រំដែនរវាងកម្ពុជានិងថៃ ប្រជាពលរដ្ឋខ្មែរជាច្រើន ដែលធ្លាប់រស់នៅ និងធ្វើការនៅប្រទេសថៃ បានវិលត្រលប់មកកាន់ព្រះរាជាណាចក្រកម្ពុជាវិញយ៉ាងគំហុក។ ក្នុងស្ថានភាពបែបនេះ រាជរដ្ឋាភិបាលកម្ពុជាដោយមានក្រសួងស្ថាប័នពាក់ព័ន្ធជាសេនាធិការ បានយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាប្រឈមជាច្រើន ដើម្បីសម្រួលដល់ការវិលត្រលប់របស់ប្រជាពលរដ្ឋខ្មែរមកកាន់មាតុប្រទេសវិញ ក្នុងនោះមានដូចជាការផ្តល់មធ្យោបាយធ្វើដំណើរ កន្លែងស្នាក់នៅបណ្តោះអាសន្ន សម្ភារៈប្រើប្រាស់ផ្សេងៗ គ្រឿងឧបភោគបរិភោគ សេវាសុខាភិបាល និងឱកាសការងារជាដើម។

ទន្ទឹមនឹងនេះ **ក្រសួងមហាផ្ទៃ** បានកត់សម្គាល់ឃើញថា ប្រជាពលរដ្ឋខ្មែរដែលទើបត្រលប់មកពីប្រទេសថៃ និងប្រជាពលរដ្ឋខ្មែរមួយចំនួនបានបាត់បង់ ខូចខាត ឬអស់សុពលភាពនូវឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ឬមិនមានឯកសារគ្រប់គ្រាន់ និងមួយចំនួនទៀតពុំទាន់មានឯកសារបញ្ជាក់អត្តសញ្ញាណប្រើប្រាស់នៅឡើយ (ដូចជាសំបុត្រកំណើត សៀវភៅស្នាក់នៅ និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជាដើម)។ បញ្ហានេះ បានបង្កជាឧបសគ្គសម្រាប់ពួកគាត់ក្នុងការស្វែងរកការងារធ្វើ ឬស្នើសុំសេវាផ្សេងៗសម្រាប់តម្រូវការប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

អនុវត្តតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម និងលិខិតបទដ្ឋានគតិយុត្តជាធរមាន **ក្រសួងមហាផ្ទៃ** សូមធ្វើការណែនាំដល់ **អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម រដ្ឋបាលរាជធានី ខេត្ត ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់** ត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយ និងខិតខំជំរុញផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរ ដោយត្រូវអនុវត្តដូចខាងក្រោម៖

### I- ការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរ ក្នុងករណីមានឯកសារភ្លាប់គ្រប់គ្រាន់សម្រាប់ស្នើសុំ ឬឯកសារបញ្ជាក់អត្តសញ្ញាណបានបាត់បង់ ខូចខាត ឬអស់សុពលភាព

ការចុះបញ្ជី និងការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរ ដែលមានឯកសារភ្ជាប់គ្រប់គ្រាន់ ឬឯកសារបញ្ជាក់អត្តសញ្ញាណបានបាត់បង់ ខូចខាត ឬអស់សុពលភាព ត្រូវអនុវត្តដូចខាងក្រោម៖

១. ចំពោះប្រជាពលរដ្ឋខ្មែរដែលមានឯកសារគ្រប់គ្រាន់សម្រាប់ស្នើសុំចុះបញ្ជីកំណើត ចុះបញ្ជីស្នាក់នៅ និងចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ក្នុងការចុះបញ្ជី និងផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស ស្របតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

២. ចំពោះប្រជាពលរដ្ឋខ្មែរដែលសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតបានបាត់បង់ ឬខូចខាត នាយកដ្ឋានអត្រានុកូលដ្ឋាន រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវយកចិត្តទុកដាក់ចេញសេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ជូនអ្នកស្នើសុំឱ្យបានឆាប់រហ័ស ស្របតាមបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។

៣. ចំពោះប្រជាពលរដ្ឋខ្មែរដែលសៀវភៅស្នាក់នៅបានបាត់បង់ ឬខូចខាត នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ត្រូវចេញសៀវភៅស្នាក់នៅទុតិយតា ជូនអ្នកស្នើសុំឱ្យបានឆាប់រហ័ស ស្របតាមបែបបទ និងនីតិវិធីនៃការងារចុះបញ្ជី និងគ្រប់គ្រងការស្នាក់នៅ។

៤. ចំពោះប្រជាពលរដ្ឋខ្មែរដែលអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរអស់សុពលភាព ឬមានសុពលភាពនៅតិចជាង ១៨០ថ្ងៃ ឬបាត់បង់ ឬខូចខាត មន្ត្រីទទួលបន្ទុកការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនៅតាមទីតាំងផ្តល់សេវានីមួយៗ ត្រូវបំពេញបែបបទ ដើម្បីស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតាជូនអ្នកស្នើសុំ ស្របតាមបែបបទ និងនីតិវិធីនៃការងារចុះបញ្ជី និងផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

**II- ការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរ ក្នុងករណីពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារបញ្ជាក់អត្តសញ្ញាណច្បាស់លាស់**

ការចុះបញ្ជី និងការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរ ក្នុងករណីពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារបញ្ជាក់អត្តសញ្ញាណច្បាស់លាស់ ត្រូវសម្រេចដោយក្រុមការងារកំណត់អត្តសញ្ញាណឃុំ សង្កាត់។ ក្រុមការងារកំណត់អត្តសញ្ញាណឃុំ សង្កាត់ និងបែបបទនៃការចុះបញ្ជី ព្រមទាំងការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរ ត្រូវអនុវត្តដូចខាងក្រោម៖

**ក. ក្រុមការងារកំណត់អត្តសញ្ញាណឃុំ សង្កាត់**

ក្រុមការងារកំណត់អត្តសញ្ញាណឃុំ សង្កាត់ មានសមាសភាព (១) មេឃុំ ចៅសង្កាត់ (២) នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ (៣) ស្មៀនឃុំ សង្កាត់ និង (៤) មេភូមិសាមី។ ក្រុមការងារកំណត់អត្តសញ្ញាណនេះដឹកនាំដោយ មេឃុំ ចៅសង្កាត់ និងមានភារកិច្ចដូចខាងក្រោម៖

- សម្ភាស និងធ្វើកំណត់ហេតុសាកសួរអ្នកស្នើសុំ ដោយមានការចូលរួមពីសាក្សី ១រូប ជាពលរដ្ឋខ្មែរដែលមានអត្តសញ្ញាណច្បាស់លាស់ ដើម្បីពិនិត្យ វាយតម្លៃ និងកំណត់អត្តសញ្ញាណអ្នកស្នើសុំនោះថាជាពលរដ្ឋខ្មែរ ឬមិនមែនជាពលរដ្ឋខ្មែរ
- ក្រុមការងារកំណត់អត្តសញ្ញាណ មិនត្រូវបដិសេធក្នុងការចុះបញ្ជីជូនអ្នកស្នើសុំទេ ក្នុងករណីដែលរកឃើញថាសាមីខ្លួនជាពលរដ្ឋខ្មែរពិតប្រាកដ
- ក្នុងករណីចាំបាច់ ក្រុមការងារកំណត់អត្តសញ្ញាណ អាចសាកសួរព័ត៌មានបន្ថែម ពីសាច់ញាតិអ្នកជិតខាង ឬចាស់ព្រឹទ្ធាចារ្យ ដើម្បីកំណត់អត្តសញ្ញាណ
- ករណីសាមីខ្លួនមិនមានលំនៅឋានច្បាស់លាស់ ក្រុមការងារត្រូវពិនិត្យ និងកំណត់ទីសំណាក់ដែលជាអាសយដ្ឋាន ដើម្បីបន្តបែបបទចុះបញ្ជី
- ក្រុមការងារកំណត់អត្តសញ្ញាណ ត្រូវធ្វើកំណត់ហេតុសាកសួរចំនួន ២ច្បាប់ ដោយ ១ច្បាប់រក្សាទុកនៅរដ្ឋបាលឃុំ សង្កាត់ និង ១ច្បាប់ទៀត រក្សាទុកនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់។

**ខ. ការចុះបញ្ជី និងការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរ**

ការសម្រេចក្នុងការចុះបញ្ជី និងការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរ ដែលពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំទាន់មានឯកសារបញ្ជាក់អត្តសញ្ញាណច្បាស់លាស់ ត្រូវអនុវត្តដូចខាងក្រោម៖

**១. ការចុះបញ្ជីកំណើត និងការផ្តល់សំបុត្រកំណើត**

ចំពោះពលរដ្ឋដែលមកស្នើសុំចុះបញ្ជីកំណើត តែពុំទាន់មានឯកសារភ្ជាប់គ្រប់គ្រាន់ ឬពុំមានឯកសារបញ្ជាក់អត្តសញ្ញាណច្បាស់លាស់ សាមីខ្លួនត្រូវនាំមកជាមួយនូវសាក្សីចំនួន ១រូប។ បន្ទាប់មកក្រុមការងារកំណត់សញ្ជាណ ត្រូវអនុវត្តដូចខាងក្រោម៖

- ក្នុងករណីពិនិត្យឃើញថា អ្នកស្នើសុំជាពលរដ្ឋខ្មែរពិតប្រាកដ ក្រុមការងារកំណត់អត្តសញ្ញាណ ត្រូវសម្រេចឱ្យមន្ត្រីអត្រានុកូលដ្ឋាន ចុះបញ្ជីកំណើត និងផ្តល់សំបុត្រកំណើតជូនអ្នកស្នើសុំ។ កំណត់ហេតុសាកសួរបញ្ជាក់អត្តសញ្ញាណនោះ ត្រូវកំណត់យកជាឯកសារភ្ជាប់សម្រាប់ចុះបញ្ជីកំណើត។
- ក្នុងករណីមិនអាចកំណត់អត្តសញ្ញាណបានថាជាពលរដ្ឋខ្មែរ ក្រុមការងារកំណត់អត្តសញ្ញាណត្រូវរាយការណ៍តាមឋានានុក្រមរដ្ឋបាលការងារទៅកាន់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដើម្បីបន្តនីតិវិធីស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

កំណត់ហេតុសាកសួរបញ្ជាក់អត្តសញ្ញាណសម្រាប់ប្រជាពលរដ្ឋខ្មែរ ក្នុងករណីពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារបញ្ជាក់អត្តសញ្ញាណច្បាស់លាស់**ជាឧបសម្ព័ន្ធទី១** នៃសេចក្តីណែនាំនេះ។

**២. ការចុះបញ្ជីស្នាក់នៅ និងការផ្តល់សៀវភៅស្នាក់នៅ**

ចំពោះពលរដ្ឋ ដែលមកស្នើសុំចុះបញ្ជីស្នាក់នៅ តែពុំទាន់មានឯកសារភ្ជាប់គ្រប់គ្រាន់ ឬពុំមានឯកសារបញ្ជាក់អត្តសញ្ញាណច្បាស់លាស់ សាមីខ្លួនត្រូវនាំមកជាមួយនូវសាក្សីចំនួន ១រូប ដូចមានចែងក្នុងចំណុច ខ.១ ខាងលើ បន្ទាប់មកត្រូវអនុវត្តដូចខាងក្រោម៖

- ក្នុងករណីពិនិត្យឃើញថា អ្នកស្នើសុំជាពលរដ្ឋខ្មែរពិតប្រាកដ ក្រុមការងារកំណត់អត្តសញ្ញាណត្រូវសម្រេចឱ្យមន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ចុះឈ្មោះក្នុងបញ្ជីស្នាក់នៅ និងផ្តល់សៀវភៅស្នាក់នៅ ជូនអ្នកស្នើសុំ។ កំណត់ហេតុសាកសួរបញ្ជាក់អត្តសញ្ញាណ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ ត្រូវយកជាឯកសារភ្ជាប់សម្រាប់ចុះបញ្ជីស្នាក់នៅ។
- ក្នុងករណីមិនអាចកំណត់អត្តសញ្ញាណបានថាជាពលរដ្ឋខ្មែរ ក្រុមការងារកំណត់អត្តសញ្ញាណ ត្រូវរាយការណ៍តាមឋានានុក្រមរដ្ឋបាលការងារទៅកាន់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដើម្បីបន្តនីតិវិធីស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**៣. ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ**

ប្រជាពលរដ្ឋដែលមកស្នើសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ តែពុំទាន់មានឯកសារភ្ជាប់គ្រប់គ្រាន់ ឬពុំមានឯកសារបញ្ជាក់អត្តសញ្ញាណច្បាស់លាស់ មន្ត្រីទទួលបន្ទុកការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវណែនាំឱ្យសាមីខ្លួនទៅចុះបញ្ជីកំណើត និង/ឬបញ្ជីស្នាក់នៅជាមុនសិន ទើបអាចបន្តនីតិវិធីនៃការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបាន។

III- **យន្តការគាំទ្រ តាមដាន និងត្រួតពិនិត្យលើការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរ**

១. **អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** ត្រូវសហការ និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការពន្លឿនការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរ និងត្រូវធ្វើរបាយការណ៍ជូនក្រសួងមហាផ្ទៃ ដូចទម្រង់ក្នុង**ឧបសម្ព័ន្ធទី២** នៃសេចក្តីណែនាំនេះ។

២. **រដ្ឋបាលរាជធានី ខេត្ត ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ** ត្រូវជំរុញការផ្សព្វផ្សាយ និងគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ក្នុងការពន្លឿនការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរឱ្យបានគ្រប់គ្នា ទាំងប្រជាពលរដ្ឋខ្មែរដែលទើបវិលត្រលប់ពីប្រទេសថៃ និងប្រជាពលរដ្ឋខ្មែរដែលពុំទាន់មានឯកសារគ្រប់គ្រាន់ "**ដោយមិនត្រូវទុកប្រជាពលរដ្ឋខ្មែរណាម្នាក់គ្មានឯកសារបញ្ជាក់អត្តសញ្ញាណប្រើប្រាស់ឡើយ**"។

៣. **រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់** ត្រូវបញ្ជូនរបាយការណ៍ប្រចាំខែតាមហានានុក្រមមកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ជារៀងរាល់ខែ ដូចទម្រង់ក្នុង**ឧបសម្ព័ន្ធទី៣ ឧបសម្ព័ន្ធទី៤ និងឧបសម្ព័ន្ធទី៥** នៃសេចក្តីណែនាំនេះ។

អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើការណែនាំពន្យល់បន្ថែមជូនប្រជាពលរដ្ឋដែលមកស្នើសុំអំពីផលវិបាកនៃការចុះបញ្ជីស្ទួនឬចុះម្តងទៀតតែខុសទិន្នន័យ និងការទទួលខុសត្រូវផ្ទែកព្រហ្មទណ្ឌចំពោះការផ្តល់ព័ត៌មាន ឬឯកសារក្លែងក្លាយដោយចេតនា សម្រាប់ការចុះបញ្ជី ការកត់ត្រា ឬការជូនដំណឹង។

ទទួលបានសេចក្តីណែនាំនេះ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងអគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានស្ថាប័ន/អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវអនុវត្តតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ៤ កើត ខែ ភ្មេសាឆ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣៧ ខែកុម្ភៃ ឆ្នាំ២០២៥
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អតិសន្តិបណ្ឌិត ស សុខា**

<u>**កន្លែងទទួល**</u>**:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
  ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំលេខ.០៤០.....សណន ចុះថ្ងៃទី.២៧...ខែ.សីហា..ឆ្នាំ២០២៤

ស្តីពីការដំរុញការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណដល់ប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់ពីប្រទេសថៃ
និងប្រជាពលរដ្ឋខ្មែរដែលពុំទាន់មានឯកសារគ្រប់គ្រាន់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំណត់ហេតុ**
**សាកសួរបញ្ជាក់អត្តសញ្ញាណសម្រាប់ប្រជាពលរដ្ឋខ្មែរ**
**ក្នុងករណីពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារបញ្ជាក់អត្តសញ្ញាណច្បាស់លាស់**

ថ្ងៃ.....ខែ.....ថ្ងៃទី.....វេលាម៉ោង.....
នៅរដ្ឋបាលឃុំ សង្កាត់.....ក្រុង ស្រុក ខណ្ឌ.....រាជធានី ខេត្ត.....
លោក/លោកស្រីជាមេឃុំ ចៅសង្កាត់..... បានដឹកនាំសាកសួរ និងកំណត់អត្តសញ្ញាណ
របស់ឈ្មោះ.....កេទ..... ក្នុងគោលបំណងប្រើប្រាស់ដើម្បីចុះបញ្ជីកំណើត
និងចុះបញ្ជីស្នាក់នៅ។

**សមាសភាពចូលរួមមាន៖**
- លោក/លោកស្រី..... ជាមេឃុំ ចៅសង្កាត់.....
- លោក/លោកស្រី..... ជានាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់.....
- លោក/លោកស្រី..... ជាស្មៀនឃុំ សង្កាត់.....
- លោក/លោកស្រី..... ជាមេភូមិ (សាមី).....
- លោក/លោកស្រី..... ជាសាក្សីជឹងឮ។

**១. ព័ត៌មានសាមីខ្លួន**
- គោត្តនាម និងនាម : ..... កេទ : .....
- ឈ្មោះជាអក្សរឡាតាំង: ..... ជនជាតិ : .....
- ថ្ងៃ ខែ ឆ្នាំកំណើត : ..... សញ្ជាតិ : .....
- ទីកន្លែងកំណើត : .....
- ស្ថានភាពគ្រួសារ : ☐ នៅលីវ ☐ មានគ្រួសារ ☐ មេម៉ាយ ឬពោះម៉ាយ
- មុខរបរ : .....
- លំនៅឋានបច្ចុប្បន្ន : .....
- កម្រិតវប្បធម៌ : ..... ជំនាញឯកទេស : .....
- ចំណេះដឹងភាសាខ្មែរ: និយាយ.....ស្តាប់.....សរសេរ.....អាន.....
- ភាសាបរទេស : .....
- លេខទំនាក់ទំនងសាមីខ្លួន : .....
- ឯកសារដែលមាន : ☐ គ្មានឯកសារ ☐ លិខិតធ្វើដំណើរពលករកម្ពុជាទៅធ្វើការនៅបរទេស
  ☐ ឯកសារផ្សេងទៀត .....

**២. ព័ត៌មានឪពុក**
- គោត្តនាម និងនាម : ..... ជនជាតិ : .....
- ថ្ងៃ ខែ ឆ្នាំកំណើត : ..... សញ្ជាតិ : .....
- ទីកន្លែងកំណើត : .....
- មុខរបរ : ..... ស្ថានភាព : ☐ រស់ ☐ ស្លាប់
- លំនៅឋានបច្ចុប្បន្ន : .....

៣. ព័ត៌មានម្តាយ

- គោត្តនាម និងនាម : ..... ជនជាតិ : .....
- ថ្ងៃ ខែ ឆ្នាំកំណើត : ..... សញ្ជាតិ : .....
- ទីកន្លែងកំណើត : .....
- មុខរបរ : ..... ស្ថានភាព : ☐ រស់ ☐ ស្លាប់
- លំនៅឋានបច្ចុប្បន្ន : .....

៤. ព័ត៌មានប្តី ឬប្រពន្ធ (ក្នុងករណីមានប្តីប្រពន្ធ)

- គោត្តនាម និងនាម : ..... ជនជាតិ : .....
- ថ្ងៃ ខែ ឆ្នាំកំណើត : ..... សញ្ជាតិ : .....
- ទីកន្លែងកំណើត : .....
- មុខរបរ : ..... ស្ថានភាព : ☐ រស់ ☐ ស្លាប់
- លំនៅឋានបច្ចុប្បន្ន : .....

៥. ព័ត៌មានកូន (ក្នុងករណីមាន)

- គោត្តនាម និងនាម : ..... ឆ្នាំកំណើត:.....
- គោត្តនាម និងនាម : ..... ឆ្នាំកំណើត:.....
- គោត្តនាម និងនាម : ..... ឆ្នាំកំណើត:.....

**៦. ការធានាអះអាងពីសាមីខ្លួន**

ខ្ញុំសូមធានាអះអាងថា រាល់ព័ត៌មានបញ្ជាក់ខាងលើនេះពិតជាត្រឹមត្រូវប្រាកដមែន ប្រសិនបើខុសពីការពិត ខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន។

**៧. ការវាយតម្លៃរបស់ក្រុមការងារកំណត់អត្តសញ្ញាណ**

ឈ្មោះ.....ថ្ងៃខែឆ្នាំកំណើត..... ☐ ជាពលរដ្ឋខ្មែរ

☐ មិនអាចកំណត់អត្តសញ្ញាណថាជាពលរដ្ឋខ្មែរ ដោយមូលហេតុ.....។

កំណត់ហេតុនេះត្រូវបានបញ្ចប់នៅវេលាម៉ោង..... នាថ្ងៃខែឆ្នាំដដែល ដោយបានអានឱ្យសាមីខ្លួនស្តាប់ និងបញ្ជាក់ថាកំណត់ហេតុនេះពិតជាត្រឹមត្រូវ រួចសាមីខ្លួនបានផ្តិតស្នាមមេដៃស្តាំទុកជាភស្តុតាង។

**ស្នាមមេដៃសាមីខ្លួន** **ស្នាមមេដៃសាក្សីដើមបណ្តឹង** **ហត្ថលេខាមេភូមិ** **ហត្ថលេខាស្មៀន**

| | |
|---|---|
| លេខ : ..... | លេខ : ..... |
| **បានឃើញ និងឯកភាព** | **បានឃើញ និងឯកភាព** |
| ថ្ងៃ.....ខែ.....ឆ្នាំ.....ស័ក ព.ស.២៥.... | ថ្ងៃ.....ខែ.....ឆ្នាំ.....ស័ក ព.ស.២៥.... |
| .....ថ្ងៃទី..... ខែ.....ឆ្នាំ២០២.. | .....ថ្ងៃទី ..... ខែ.....ឆ្នាំ២០២.. |
| **មេឃុំ ចៅសង្កាត់**..... | **នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់**..... |

ឧបសម្ព័ន្ធទី២ នៃសេចក្តីណែនាំលេខ.....០៥០.....សណន ចុះថ្ងៃទី.....២៧.....ខែ.....សីហា.....ឆ្នាំ.....២០២៥ ស្តីពីការជំរុញការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ
ដល់ប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់ពីប្រទេសថៃ និងប្រជាពលរដ្ឋខ្មែរដែលពុំទាន់មានឯកសារគ្រប់គ្រាន់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**
**លេខ .....**

## របាយការណ៍ស្តីពីការជំរុញផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ
## ជូនប្រជាពលរដ្ឋខ្មែរដែលធើបវិលត្រលប់ពីប្រទេសថៃ និងប្រជាពលរដ្ឋខ្មែរដែលពុំទាន់មានឯកសារគ្រប់គ្រាន់

គិតចាប់ពីថ្ងៃទី.....ខែ.....ឆ្នាំ.....ដល់ថ្ងៃទី.....ខែ.....ឆ្នាំ.....

| ល.រ | រាជធានី ខេត្ត | ប្រជាពលរដ្ឋខ្មែរត្រលប់ពីថៃ ដែលមានឯកសារភ្ជាប់គ្រប់គ្រាន់ (រូប) | | | | ប្រជាពលរដ្ឋខ្មែរត្រលប់ពីថៃ ដែលពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ (រូប) | | | | ប្រជាពលរដ្ឋខ្មែរ ដែលពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ (រូប) | | | | អ្នកស្នើសុំ ដែលពុំអាចកំណត់អត្តសញ្ញាណបាន (រូប) | | ប្រជាពលរដ្ឋខ្មែរដែលត្រលប់ពីថៃបានចុះបញ្ជី (3+4) (រូប) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | | បដិសេធចុះបញ្ជី | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| (1) | (2) | (3) | | | | (4) | | | | (5) | | | | (6) | | (7) | | | |
| ១ | | | | | | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | | | | | | | |
| សរុប | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

បានឃើញ និងឯកភាព
ថ្ងៃ.....ខែ..... ឆ្នាំ.....ស័ក ព.ស.២៥.....
..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....
**អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

ថ្ងៃ.....ខែ..... ឆ្នាំ.....ស័ក ព.ស.២៥.....
..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....
**ប្រធាននាយកដ្ឋានរដ្ឋបាល-សរុប**

ឧបសម្ព័ន្ធទី៣ នៃសេចក្តីណែនាំលេខ.....០៤០.....សណន ចុះថ្ងៃទី...២៧...ខែ...សីហា...ឆ្នាំ...២០២៤... ស្តីពីការជំរុញការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ
ដល់ប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់ពីប្រទេសថៃ និងប្រជាពលរដ្ឋខ្មែរដែលពុំទាន់មានឯកសារគ្រប់គ្រាន់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី ខេត្ត.....**
**លេខ .....**

## របាយការណ៍ស្តីពីការជំរុញផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ
## ជូនប្រជាពលរដ្ឋខ្មែរដែលធើបទិលត្រលប់ពីប្រទេសថៃ និងប្រជាពលរដ្ឋខ្មែរដែលពុំទាន់មានឯកសារគ្រប់គ្រាន់

គិតចាប់ពីថ្ងៃទី.....ខែ.....ឆ្នាំ.....ដល់ថ្ងៃទី.....ខែ.....ឆ្នាំ.....

| ល.រ | ក្រុង ស្រុក ខណ្ឌ | ប្រជាពលរដ្ឋខ្មែរត្រលប់ពីថៃ ដែលមានឯកសារភ្ជាប់គ្រប់គ្រាន់ (រូប) | | | | ប្រជាពលរដ្ឋខ្មែរត្រលប់ពីថៃ ដែលពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ (រូប) | | | | ប្រជាពលរដ្ឋខ្មែរ ដែលពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ (រូប) | | | | អ្នកស្នើសុំ ដែលពុំអាចកំណត់អត្តសញ្ញាណបាន (រូប) | | ប្រជាពលរដ្ឋខ្មែរដែលត្រលប់ពីថៃបានចុះបញ្ជី (3+4) (រូប) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | | បដិសេធចុះបញ្ជី | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| (1) | (2) | (3) | | | | (4) | | | | (5) | | | | (6) | | (7) | | | |
| ១ | | | | | | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | | | | | | |
| សរុប | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

<u>**កំណត់សម្គាល់**</u>៖ រដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជូនរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៅថ្ងៃទី១៥ នៃខែបន្ទាប់។

ថ្ងៃ.....ខែ..... ឆ្នាំ.....ស័ក ព.ស.២៥.....

.....ថ្ងៃទី..... ខែ..... ឆ្នាំ២០.....
**នាយកទីចាត់ការរដ្ឋបាល**

ថ្ងៃ.....ខែ..... ឆ្នាំ.....ស័ក ព.ស.២៥.....
.....ថ្ងៃទី..... ខែ..... ឆ្នាំ២០.....
**សួងការនគរបាលរាជធានី ខេត្ត.....**

បានឃើញ និងឯកភាព
ថ្ងៃ.....ខែ..... ឆ្នាំ.....ស័ក ព.ស.២៥.....
.....ថ្ងៃទី..... ខែ..... ឆ្នាំ២០.....
**អតិបាលរាជធានី ខេត្ត.....**

ឧបសម្ព័ន្ធទី៤ នៃសេចក្តីណែនាំលេខ.....សណន ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....ស្តីពីការដំរុញការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ
ដល់ប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់ពីប្រទេសថៃ និងប្រជាពលរដ្ឋខ្មែរដែលពុំទាន់មានឯកសារគ្រប់គ្រាន់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី ខេត្ត.....**
**រដ្ឋបាលក្រុង ស្រុក ខណ្ឌ.....**
**លេខ .....**

## របាយការណ៍ស្តីពីការដំរុញផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ
## ជូនប្រជាពលរដ្ឋខ្មែរដែលទើបវិលត្រលប់ពីប្រទេសថៃ និងប្រជាពលរដ្ឋខ្មែរដែលពុំទាន់មានឯកសារគ្រប់គ្រាន់

គិតចាប់ពីថ្ងៃទី.....ខែ.....ឆ្នាំ.....ដល់ថ្ងៃទី.....ខែ.....ឆ្នាំ.....

| ល.រ | ឃុំ សង្កាត់ | ប្រជាពលរដ្ឋខ្មែរត្រលប់ពីថៃ ដែលមានឯកសារភ្ជាប់គ្រប់គ្រាន់ (រូប) | | | | ប្រជាពលរដ្ឋខ្មែរត្រលប់ពីថៃ ដែលពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ (រូប) | | | | ប្រជាពលរដ្ឋខ្មែរ ដែលពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ (រូប) | | | | អ្នកស្នើសុំដែលពុំអាចកំណត់អត្តសញ្ញាណបាន (រូប) | | ប្រជាពលរដ្ឋខ្មែរដែលត្រលប់ពីថៃបានចុះបញ្ជី (3+4) (រូប) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | | បដិសេធចុះបញ្ជី | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| (1) | (2) | (3) | | | | (4) | | | | (5) | | | | (6) | | (7) | | | |
| ១ | | | | | | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | | | | | | |
| សរុប | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

<u>កំណត់សម្គាល់</u>៖ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនរបាយការណ៍ប្រចាំខែ មករដ្ឋបាលរាជធានី ខេត្ត នៅថ្ងៃទី១០ នៃខែបន្ទាប់។

ថ្ងៃ.....ខែ..... ឆ្នាំ.....ស័ក ព.ស.២៥.....

បានឃើញ និងឯកភាព
ថ្ងៃ.....ខែ..... ឆ្នាំ.....ស័ក ព.ស.២៥.....
..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....
**អភិបាលក្រុង ស្រុក ខណ្ឌ.....**

ថ្ងៃ.....ខែ..... ឆ្នាំ.....ស័ក ព.ស.២៥.....
..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....
**អធិការនគរបាលក្រុង ស្រុក ខណ្ឌ.....**

..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....
**ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក/ហិរញ្ញវត្ថុ**

ឧបសម្ព័ន្ធទី៥ នៃសេចក្តីណែនាំលេខ.....០៤០.....សណន ចុះថ្ងៃទី...២៧...ខែ...តឹហា...ឆ្នាំ...២៧៥... ស្តីពីការជំរុញការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ
ដល់ប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់ពីប្រទេសថៃ និងប្រជាពលរដ្ឋខ្មែរដែលពុំទាន់មានឯកសារគ្រប់គ្រាន់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី ខេត្ត.....**
**រដ្ឋបាលក្រុង ស្រុក ខណ្ឌ.....**
**រដ្ឋបាលឃុំ សង្កាត់.....**
**លេខ .....**

## របាយការណ៍ស្តីពីការជំរុញផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ
## ជូនប្រជាពលរដ្ឋខ្មែរដែលធើបវិលត្រលប់ពីប្រទេសថៃ និងប្រជាពលរដ្ឋខ្មែរដែលពុំទាន់មានឯកសារគ្រប់គ្រាន់

គិតចាប់ពីថ្ងៃទី.....ខែ.....ឆ្នាំ.....ដល់ថ្ងៃទី.....ខែ.....ឆ្នាំ.....

| ល.រ | ភូមិ | ប្រជាពលរដ្ឋខ្មែរត្រលប់ពីថៃ ដែលមានឯកសារភ្ជាប់គ្រប់គ្រាន់ (រូប) | | | | ប្រជាពលរដ្ឋខ្មែរត្រលប់ពីថៃ ដែលពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ (រូប) | | | | ប្រជាពលរដ្ឋខ្មែរ ដែលពុំទាន់មានឯកសារគ្រប់គ្រាន់ ឬពុំមានឯកសារអត្តសញ្ញាណច្បាស់លាស់ (រូប) | | | | អ្នកស្នើសុំ ដែលពុំអាចកំណត់អត្តសញ្ញាណបាន (រូប) | | ប្រជាពលរដ្ឋខ្មែរដែលត្រលប់ពីថៃបានចុះបញ្ជី (3+4) (រូប) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | | បដិសេធចុះបញ្ជី | | ចុះបញ្ជីកំណើត | | ចុះបញ្ជីស្នាក់នៅ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| (1) | (2) | (3) | | | | (4) | | | | (5) | | | | (6) | | (7) | | | |
| ១ | | | | | | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | | | | | | |
| សរុប | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

<u>**កំណត់សម្គាល់**</u>៖ រដ្ឋបាលឃុំ សង្កាត់ ត្រូវបញ្ជូនរបាយការណ៍ប្រចាំខែ មករដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅថ្ងៃទី៥ នៃខែបន្ទាប់។

បានឃើញ និងឯកភាព
ថ្ងៃ.....ខែ..... ឆ្នាំ.....ស័ក ព.ស.២៥.....
..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....
**មេឃុំ ចៅសង្កាត់.....**

ថ្ងៃ.....ខែ..... ឆ្នាំ.....ស័ក ព.ស.២៥.....
..... ថ្ងៃទី..... ខែ..... ឆ្នាំ២០.....
**នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់.....**